**បានកែសម្រួល៖** ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០២៣

# ការយល់ដឹងអំពី ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា នៃដំណើរការជ្រើសរើសសាលា

## សេចក្តីផ្តើម

ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា គឺជាដំណើរការដែលពង្រីកទៅលើអ្វីដែលពីមុនត្រូវបានគេស្គាល់ថាជា ការពិនិត្យឡើងវិញដោយមិនលំអៀង LeGare (LeGare Impartial Review)។ ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាកើតឡើងនៅពេលដែលសិស្សដាក់ពាក្យសុំចូលរៀនតាមកម្រិតថ្នាក់ក្នុងកម្មវិធីអនុវិទ្យាល័យ ឬវិទ្យាល័យ ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ។ ដំណើរការនេះអនុញ្ញាតឱ្យសិស្សដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់មួយចំនួនមានឱកាសទទួលការបោះបង់លក្ខណៈវិនិច្ឆ័យ មួយ (១) ដើម្បីឱ្យក្រុមពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាកំណត់សិទ្ធិសម្រាប់សាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ។ ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាគឺជាដំណើរការប្តឹងតវ៉ា សម្រាប់សិស្សដែលមិនអ្វីត្រូវតាមតម្រូវការនៃសិទ្ធិទទួលមួយ ដើម្បីកំណត់ថាតើសាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យនីមួយៗដែលសិស្សកំពុងស្នើសុំចូលរៀនអាចផ្តល់ការគាំទ្រសមរម្យបានដែរឬអត់។ ការណែនាំ និងព័ត៌មានបន្ថែម អាចរកឃើញនៅលើ [ទំព័រនៃការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា (Individualized Review page)](Individualized Review page) នៃគេហទំព័រជ្រើសរើសសាលា។

### តើអ្នកណាអាចមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា

សិស្សអាចទទួលការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា ប្រសិនបើពួកគេកំពុងដាក់ពាក្យទៅសាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យតាមកម្រិតថ្នាក់ ហើយត្រូវតាមប្រភេទមួយ ឬច្រើនជាង ដូចមានខាងក្រោមនេះ៖

- មានពិការភាពដែលមាន IEP នាបច្ចុប្បន្ននេះ ឬ
- មាន 504 plan នាបច្ចុប្បន្ននេះ ឬមានសិទ្ធិសម្រាប់ 504 ឬ
- បច្ចុប្បន្ននេះកំពុងទទួលសេវាកម្មសម្រាប់ សិស្សដែលត្រូវរៀនអង់គ្លេស (EL)។

សិស្សដែលត្រូវតាមប្រភេទនេះ ហើយជ្រើសរើសការបោះបង់លក្ខណៈវិនិច្ឆ័យ មួយ (១) ដូចបានកត់សម្គាល់នៅក្នុងពាក្យស្នើសុំរបស់ពួកគេ អាចទទួលការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា ដើម្បីសម្រេចថាតើពួកគេត្រូវបានដាក់ចូលទៅក្នុងឆ្នោតរបស់សាលានោះឬអត់។ អ្នកដាក់ពាក្យត្រូវតែត្រូវតាមលក្ខណៈវិនិច្ឆ័យ ពីរ (២) សម្រាប់សាលាដែលពួកគេកំពុងដាក់ពាក្យស្នើសុំ ដើម្បីមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា។ បន្ថែមពីលើការជ្រើសរើសលក្ខណៈវិនិច្ឆ័យដើម្បីបោះបង់ អ្នកដាក់ពាក្យក៏ត្រូវតែផ្តល់ ឯកសារបន្ថែមសម្រាប់ការទទួលឱ្យចូលរៀន (Admissions Addendum) ដែលពេញលេញ និងឯកសារគាំទ្រផងដែរ។ ឯកសារទាំងនេះត្រូវបានស្នើសុំនៅក្នុង លិខិតដាក់ពាក្យ SchoolMint ។ បេក្ខជនដែលមិនផ្តល់ឯកសារទាំងនេះនឹងមិនទទួលការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាទេ។

ដំណើរការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាមិនធានានូវសិទ្ធិទទួលឆ្នោតរបស់សាលា ឬឆ្នោតរបស់កម្មវិធីនោះទេ ហើយមិនធានាថាសិស្សដែលទទួលការបោះបង់លក្ខខណៈវិនិច្ឆ័យណាមួយនឹងត្រូវបានអនុញ្ញាតឱ្យចូលរៀននៅសាលា ឬកម្មវិធីដែលផ្អែកលើលក្ខណៈវិនិច្ឆ័យនោះទេ។

## ហេតុអ្វីបានជាអ្នកដាក់ពាក្យស្នើសុំមិនមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា

សិស្សមួយចំនួនដែលបច្ចុប្បន្ននេះមាន IEP, 504 plan/សិទ្ធិទទួល 504 ឬសេវា EL អាចដាក់ពាក្យទៅសាលា ឬកម្មវិធីដែលផ្អែកលើលក្ខណៈវិនិច្ឆ័យតាមកម្រិតថ្នាក់ ហើយនៅតែមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា។ មូលហេតុផ្សេងៗដែលសិស្សមិនអាចទទួលការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា រួមមាន៖

- សិស្សដាក់ពាក្យទៅតែ សាលានៅក្នុងតំបន់ ឬសាលាទូទាំងទីក្រុង តែប៉ុណ្ណោះ។
- សិស្សមិនបានស្នើសុំការបោះបង់លក្ខណៈវិនិច្ឆ័យណាមួយ។
- សិស្សបានបោះបង់លក្ខណៈវិនិច្ឆ័យខុស (ឧទាហរណ៍ ពួកគេមិនបំពេញតាមលក្ខណៈវិនិច្ឆ័យនៃវត្តមានអវត្តមានសម្រាប់សាលានោះ ប៉ុន្តែបានប្រាប់នៅលើពាក្យស្នើសុំរបស់ពួកគេថា ពួកគេចង់បោះបង់ ការវាយតម្លៃតាមស្តង់ដារ (standardized assessments))។
- សិស្សមិនបានបញ្ជូនឯកសារគាំទ្រ (រួមទាំង ឯកសារបន្ថែមសម្រាប់ការទទួលឱ្យចូលរៀន Admissions Addendum)។
- សិស្សត្រូវបោះបង់លក្ខខណៈវិនិច្ឆ័យនៃសិទ្ធិទទួលលើសពីមួយ។
    - សិស្សត្រូវតែបំពេញតាមលក្ខណៈវិនិច្ឆ័យពីរ ក្នុងចំណោមលក្ខណៈវិនិច្ឆ័យបី សម្រាប់សាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលពួកគេជ្រើសរើសដើម្បីមានលក្ខណៈគ្រប់

គ្រាន់សម្រាប់ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា។

- សិស្សមានសិទ្ធិចូលរៀននៅសាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលពួកគេបានដាក់ពាក្យទៅ យ៉ាងហោចណាស់មួយ។
  - ប្រសិនបើអ្នកដាក់ពាក្យស្នើសុំមានសិទ្ធិចូលរៀននៅសាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ**ណាមួយ**ដែលពួកគេបានដាក់ពាក្យទៅ ពួកគេនឹងមិនទទួលការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាសម្រាប់សាលាដែលពួកគេបានដាក់ពាក្យស្នើសុំ ដែលនៅសល់ទៀយ ហើយមិនបំពេញតាមលក្ខណៈវិនិច្ឆ័យនោះ។

## <u>ពេលវេលាសម្រាប់ ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា (Individualized Review Timeline)</u>

### ថ្ងៃទី ១៥ ខែ កញ្ញា ម៉ោង ៤ រសៀល ដល់ ថ្ងៃទី ២៧ ខែ តុលា ម៉ោង ១១:៥៩ យប់

- សិស្សដែលមានសិទ្ធិ ត្រូវតែដាក់ពាក្យស្នើសុំជ្រើសរើសសាលា ហើយនៅក្នុងលិខិតដាក់ពាក្យស្នើសុំនោះ សូមប្រាប់ពីស្ថានភាពរបស់ពួកគេថា ជាសិស្សដែលមាន IEP, 504 plan/សិទ្ធិទទួល 504 ឬសេវា EL នាបច្ចុប្បន្ននេះ ហើយកំណត់លក្ខណៈវិនិច្ឆ័យដែលពួកគេចង់បោះបង់នៅក្នុងលិខិតដាក់ពាក្យស្នើសុំនោះដោយផ្ទាល់។
  - ក្រុមគ្រួសារត្រូវសហការយ៉ាងជិតស្និទ្ធជាមួយអ្នកផ្តល់ឱវាទរបស់សិស្សពួកគាត់ ដើម្បីយល់ដឹងពីលក្ខណៈវិនិច្ឆ័យណាដែលសមស្របក្នុងការបោះបង់ ហើយស្វែងយល់ថាតើសាលា/កម្មវិធីណា ដែលស្របតាមភាពខ្លាំងពូកែ និងចំណាប់អារម្មណ៍របស់សិស្សពួកគាត់។ <u>បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា (Individualized Review Checklist)</u> ផ្តល់ការណែនាំសម្រាប់របៀបសហការដែលប្រកបដោយប្រសិទ្ធភាពជាមួយបុគ្គលិកសាលា សម្រាប់ការចូលរួមរបស់សិស្សក្នុងការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា

### ខែ វិច្ឆិកា ឆ្នាំ ២០២៣

- ក្រុមគ្រួសារនឹងទទួលព័ត៌មានថ្មីៗដែលទាក់ទងនឹងស្ថានភាពនៃសិទ្ធិទទួលរបស់សិស្សរបស់ពួកគាត់សម្រាប់ សាលារៀន/កម្មវិធី ទាំងអស់ ដែលពួកគេបានដាក់ពាក្យទៅ។ **លិខិតដាក់ពាក្យដែលនឹងត្រូវបានពិនិត្យឡើងវិញដោយក្រុមពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នានឹងមានស្ថានភាពនៃ *ការពិនិត្យឡើងវិញនូវលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនទាន់សម្រេច (Pending Additional Criteria Review)*។**

  - *សូមកត់សំគាល់ថា ស្ថានភាពនេះក៏ត្រូវបានប្រើប្រាស់សម្រាប់សិស្សដែលបានដាក់ពាក្យទៅសាលា ឬកម្មវិធីដែលបង្រៀនពីជំនាញច្បាស់លាស់ និងការបង្រៀនដែលសិស្សរៀនតាមការធ្វើដោយផ្ទាល់ និងបំពេញតាមលក្ខណៈវិនិច្ឆ័យសិក្សា ហើយមានសិទ្ធិចូលរួមក្នុងសមាសភាគនៃការបង្ហាញពីជំនាញ ឬការរៀនតាមការធ្វើដោយផ្ទាល់នៃលក្ខណៈវិនិច្ឆ័យរបស់សាលា។ វាមិនមែនសម្រាប់តែសិស្សដែលមានការពិនិត្យឡើងវិញជាលក្ខណដោយឡែកពីគ្នានោះទេ។*
- ក្រុមពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នានឹងចាប់ផ្តើមពិនិត្យមើលលិខិតដាក់ពាក្យដើម្បីសម្រេចថាតើបេក្ខជនត្រូវបានចាត់ទុកថាមានសិទ្ធិទទួលបានឆ្នោតរបស់សាលា ឬកម្មវិធី ឬអត់។

**ខែ ធ្នូ ឆ្នាំ ២០២៣**

- ក្រុមពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នានឹងបន្តការពិនិត្យមើលលិខិតដាក់ពាក្យ ដើម្បីសម្រេចថាតើបេក្ខជនត្រូវបានចាត់ទុកថាមានសិទ្ធិទទួលបានឆ្នោតរបស់សាលា ឬកម្មវិធី ឬអត់។

**ខែ មករា ឆ្នាំ ២០២៤**

- ក្រុមពិនិត្យមើលឡើងវិញជាលក្ខណដោយឡែកពីគ្នានឹងបញ្ចប់ការពិនិត្យមើលលិខិតដាក់ពាក្យដែលមានសិទ្ធិ។
- ក្រុមគ្រួសារនឹងទទួលការប្រាស្រ័យទាក់ទងដែលទាក់ទងនឹងស្ថានភាពនៃសិទ្ធិទទួលឆ្នោតរបស់សិស្សពួកគាត់ដោយផ្អែកលើការសម្រេចចិត្តដែលធ្វើឡើងដោយ ក្រុមពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា។
- សិស្សដែលត្រូវបានរកឃើញថាមានសិទ្ធិចូលរៀនដោយឆ្នោតរបស់សាលា ឬកម្មវិធី ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យ ផ្អែកលើការសម្រេចចិត្តរបស់ក្រុមពិនិត្យមើលឡើងវិញជាលក្ខណដោយឡែកពីគ្នា នឹងត្រូវបានបញ្ចូលទៅក្នុងឆ្នោតសម្រាប់ សាលា/កម្មវិធី នោះ។
- លទ្ធផលឆ្នោតនឹងត្រូវបានទាក់ទងទៅ សិស្ស/គ្រួសារ។

## <u>របៀបចាប់ផ្ដើមការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា</u>

សិស្សមានសិទ្ធិប្រើប្រាស់លិខិតដាក់ពាក្យជ្រើសរើសសាលា ដើម្បីចាប់ផ្ដើមដំណើរការ។ ផ្នែកនៃ **ការជួយសម្រួល ទៅតាមសេចក្ដីត្រូវការសម្រាប់ការអប់រំ (Education Accommodations)** ក្នុងលិខិតដាក់ពាក្យស្នើសុំ គឺជាកន្លែងដែលអ្នកដាក់ពាក្យស្នើសុំប្រាប់ពីស្ថានភាព IEP, 504 ឬ EL របស់ពួកគេ ហើយកំណត់លក្ខណៈវិនិច្ឆ័យដែលពួកគេចង់បោះបង់។ **យោងទៅលើការឆ្លើយតបរបស់ពួកគេទៅនឹងសំណួរដែលមាននៅក្នុងផ្នែកនេះ ផ្នែកបន្ថែមត្រូវបានបញ្ចូលទៅក្នុងលិខិតដាក់ពាក្យរបស់សិស្ស ដើម្បីឱ្យក្រុមគ្រួសារអាចផ្ដល់ឯកសារគាំទ្រដែលត្រូវការ។** ការណែនាំអំពីរបៀបបំពេញផ្នែកទាំងនេះដែលនៅក្នុងលិខិតដាក់ពាក្យត្រូវបានរួមបញ្ចូលខាងក្រោមនេះ។

### <u>ផ្នែកនៃ ការជួយសម្រួលទៅតាមសេចក្ដីត្រូវការសម្រាប់ការអប់រំ</u>




សិស្សដែលបានចុះឈ្មោះរៀនថ្នាក់ទី ៤ ទី ៥ ទី ៦ ឬទី ៨ បច្ចុប្បន្នតម្រូវឱ្យប្រាប់ថាតើពួកគេជាសិស្សដែលបច្ចុប្បន្ននេះមាន IEP ឬ  504 plan/មានសិទ្ធិទទួល 504 ឬទទួលសេវា EL ឬអត់។ ប្រសិនបើពួកគេមាន IEP ពួកគេនឹងត្រូវបានស្នើសុំឱ្យប្រាប់ពីប្រភេទពិការភាពចម្បងរបស់ពួកគេ។ **សម្រាប់សិស្សរបស់ក្រសួងអប់រំបច្ចុប្បន្ន ចម្លើយទៅនឹងសំណួរទាំងនេះនឹងបញ្ចូលដោយស្វ័យប្រវត្តិនៅក្នុងលិខិតដាក់ពាក្យ។** រូបភាពនៅខាងស្ដាំនៃអេក្រង់បង្ហាញពីសំណួរទាំងនេះ ដូចគ្នានឹងសំណួរដែលនៅក្នុងលិខិតដាក់ពាក្យអញ្ចឹង។

ហើយក៏មានសំណួរអំពីការបោះបង់សិទ្ធិផងដែរ ដែលបេក្ខជនអាចជ្រើសរើសបោះបង់ វត្តមានអវត្តមាន ពិន្ទុ **ឬ**ពិន្ទុពីការប្រឡង PSSA/ការវាយតម្លៃតាមវិធីផ្សេងទៀត នៅក្នុងលិខិតដាក់ពាក្យស្នើសុំរបស់ពួកគេ។ **ពួកគេអាចជ្រើសរើសបានតែមួយ ពីចំណោមនៃជម្រើសទាំងនេះ**។ ពួកគេក៏អាចជ្រើសរើសមិនបោះបង់អ្វីទាំងអស់ ឬប្រាប់ថាពួកគេជាសិស្សដែលគ្មាន IEP, 504 plan/សិទ្ធិទទួល 504 ឬសេវាកម្ម EL ។ **បេក្ខជនដែលចាប់អា រម្មណ៍ក្នុងការចូលរួមក្នុងការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នា ត្រូវតែជ្រើសរើសលក្ខណៈវិនិ ច្ឆ័យដែលសមស្របដើម្បីបោះបង់ ដោយផ្អែកលើរបាយការណ៍សិក្សា**

**របស់ពួកគេផ្ទាល់ និងរបៀបដែលរបាយការណ៍សិក្សារបស់ពួកគេប្រៀបធៀបទៅនឹងលក្ខណៈវិនិច្ឆ័យ ដែលបានចែងសម្រាប់សាលាដែលពួកគេកំពុងដាក់ពាក្យស្នើសុំ។**




កន្លែងចុះហត្ថលេខាក៏នឹងលេចឡើងផងដែរ ដែល មាតាបិតា/អាណាព្យាបាល ត្រូវតែចុះហត្ថលេខាអេឡិចត្រូនិក របស់ពួកគាត់។ បន្ទាប់ពីបានចុះហត្ថលេខាអេឡិចត្រូនិករបស់ពួកគាត់រួចហើយ អ្នកប្រើប្រាស់អាចចុចលើពាក្យ **Save & Continue** នៅផ្នែកខាងក្រោមនៃអេក្រង់ ដើម្បីបន្តទៅផ្នែកបន្ទាប់នៃលិខិតដាក់ពាក្យរបស់ពួកគាត់។







## <u>ផ្នែកសម្រាប់ឯកសារគាំទ្រការបោះបង់</u>

**ប្រសិនបើលោកអ្នកដាក់ពាក្យស្នើសុំមាន IEP, 504 plan/សិទ្ធិទទួល 504 ឬសេវាកម្ម EL ជ្រើសរើសដើម្បីបោះបង់លក្ខណៈវិនិច្ឆ័យមួយ (ទាំងពិន្ទុ វត្តមានអវត្តមាន ឬពិន្ទុពីការប្រឡង PSSA/ការវាយតម្លៃតាមវិធីផ្សេងទៀត) ផ្នែកនៃលិខិតដាក់ពាក្យនេះនឹងលេចឡើង។** ផ្នែកនេះអនុញ្ញាតឱ្យផ្តល់ព័ត៌មានសម្រាប់ដំណើរការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា។

នៅទីនេះ បេក្ខជនអាច បញ្ចូល (upload) ឯកសារបន្ថែមសម្រាប់ការទទួលឱ្យចូលរៀន (Admissions Addendum) និងឯកសារគាំទ្រសម្រាប់ការបោះបង់លក្ខណៈវិនិច្ឆ័យ។ ដើម្បីបញ្ចូលឯកសារ រកកន្លែងដែលចង់បញ្ចូល ហើយចុចលើពាក្យ ***Choose File*** ។រកមើលឯកសារ ហើយជ្រើសរើសឯកសារពីកុំព្យូទ័ររបស់លោកអ្នកដើម្បីបញ្ចូល។ អាចបញ្ចូលឯកសារបានជាច្រើន ប្រសិនបើចាំបាច់។ បន្ទាប់ពីបញ្ចូលឯកសាររួច ចុចលើពាក្យ ***Save & Continue*** ។ ប្រសិនបើលោកអ្នកត្រូវការជំនួយក្នុងការចូលប្រើ រកមើលឯកសារ ឬបញ្ចូលឯកសារ សូមពិគ្រោះជាមួយអ្នកផ្តល់ឱវាទនៅសាលា ឬអ្នកគ្រប់គ្រងនៅសាលារបស់លោកអ្នក។









## ផ្នែកនៃ ការជួយសម្រួលទៅតាមសេចក្តីត្រូវការសម្រាប់ការអប់រំពិសេស

សិស្សដែលបច្ចុប្បន្ននេះមាន IEP ដែលបានបោះបង់លក្ខណៈវិនិច្ឆ័យនៅក្នុងលិខិតដាក់ពាក្យសុំរបស់ពួកគេអាចបញ្ចូលឯកសារអប់រំពិសេសនៅក្នុងផ្នែកនៃលិខិតដាក់ពាក្យនេះ។

ឯកសារបីប្រភេទផ្សេងគ្នាត្រូវបានស្នើសុំឱ្យបញ្ចូលនៅក្នុងផ្នែកនៃលិខិតដាក់ពាក្យនេះ។ ឯកសារទាំងនេះរួមមាន៖

1. ឯកសារ IEP បច្ចុប្បន្នរបស់សិស្ស
2. របាយការណ៍តាមដានការរីកចម្រើនសម្រាប់ឆ្នាំសិក្សា ២០២២-២៩២៣ របស់ពួកគេ និង
3. ការវាយតម្លៃការផ្លាស់ប្តូរបច្ចុប្បន្នរបស់ពួកគេ។

ដើម្បីបញ្ចូលឯកសារ រកកន្លែងដែលចង់បញ្ចូល ហើយចុចលើពាក្យ ***Choose File*** ។ រកមើលឯកសារ ហើយជ្រើសរើសឯកសារពីកុំព្យូទ័ររបស់លោកអ្នកដើម្បីបញ្ចូល។ អាចបញ្ចូលឯកសារបានជាច្រើន ប្រសិនបើចាំបាច់។ បន្ទាប់ពីបញ្ចូលឯកសាររួច ចុចលើពាក្យ ***Save & Continue*** ។



## <u>ផ្នែកនៃ ការជួយសម្រួលទៅតាមសេចក្ដីត្រូវការសម្រាប់ការអប់រំ 504</u>




សិស្សដែលបច្ចុប្បន្ននេះ 504 plan ឬមានសិទ្ធិទទួល 504 ហើយដែលបានបោះបង់លក្ខណៈវិនិច្ឆ័យនៅក្នុងលិខិតដាក់ពាក្យស្នើសុំរបស់ពួកគេ អាចបញ្ចូលឯកសារគាំទ្រការអប់រំពិសេសនៅក្នុងផ្នែកនៃលិខិតដាក់ពាក្យស្នើសុំនេះ។

ផ្នែកនេះរួមបញ្ចូលកន្លែងបញ្ចូលឯកសារតែមួយប៉ុណ្ណោះសម្រាប់របាយការណ៍ 504 plan/សិទ្ធិទទួល 504 បច្ចុប្បន្ន ជាមួយនឹងឯកសារគាំទ្រផ្នែកវេជ្ជសាស្ត្រ។ ដើម្បីបញ្ចូលឯកសារ រកកន្លែងដែលចង់បញ្ចូល ហើយចុចលើពាក្យ ***Choose File***។ រកមើលឯកសារ ហើយជ្រើសរើសឯកសារពីកុំព្យូទ័ររបស់លោកអ្នកដើម្បីបញ្ចូល។ អាចបញ្ចូលឯកសារបានជាច្រើន ប្រសិនបើចាំបាច់។ បន្ទាប់ពីបញ្ចូលឯកសាររួច ចុចលើពាក្យ ***Save & Continue*** ។

## <u>ផ្នែកនៃ ការជួយសម្រួលទៅតាមសេចក្ដីត្រូវការសម្រាប់ការអប់រំ EL</u>




សិស្សដែលកំពុងទទួលសេវា EL ហើយដែលបានបោះបង់លក្ខខណៈវិនិច្ឆ័យក្នុងលិខិតដាក់ពាក្យស្នើសុំរបស់ពួកគេ អាចបញ្ចូលឯកសារអប់រំពិសេសនៅក្នុងផ្នែកនៃលិខិតដាក់ពាក្យសុំនេះ។

ផ្នែកនេះរួមបញ្ចូលកន្លែងបញ្ចូលឯកសារតែមួយប៉ុណ្ណោះសម្រាប់ពិន្ទុពីការធ្វើតេស្ត EL Access/WIDA បច្ចុប្បន្ន។ ដើម្បីបញ្ចូលឯកសារ រកកន្លែងដែលចង់បញ្ចូល ហើយចុចលើពាក្យ ***Choose File***។ រកមើលឯកសារ ហើយជ្រើសរើសឯកសារពីកុំព្យូទ័ររបស់លោកអ្នកដើម្បីបញ្ចូល។ អាចបញ្ចូលឯកសារបានជាច្រើន ប្រសិនបើចាំបាច់។ បន្ទាប់ពីបញ្ចូលឯកសាររួច ចុចលើពាក្យ ***Save & Continue*** ។

ជំហានបន្ថែមក្នុងដំណាក់កាលដាក់ពាក្យស្នើសុំ

បេក្ខជនត្រូវចាំថា ត្រូវបំពេញផ្នែកដែលនៅសេសសល់របស់លិខិតដាក់ពាក្យស្នើសុំ **ហើយបញ្ជូនលិខិតដាក់ពាក្យស្នើសុំរបស់ពួកគេឱ្យបានមុនពេលកំណត់ ម៉ោង ១១:៥៩ យប់ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០២៣។**

នៅពេលដែលព័ត៌មាននេះត្រូវបានបញ្ជូនជាផ្នែកនៃលិខិតដាក់ពាក្យស្នើសុំរួចហើយ បេក្ខជននឹងត្រូវបានចាត់ទុកថាទទួលការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា សម្រាប់សាលាណាមួយដែលពួកគេមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យ **ប្រសិនបើសិស្សមិនមានសិទ្ធិសម្រាប់សាលា ឬកម្មវិធីដែលផ្អែកលើលក្ខណៈវិនិច្ឆ័យណាមួយ** ដែលមាននៅក្នុងលិខិតដាក់ពាក្យស្នើសុំរបស់ពួកគេ។

## *ការទំនាក់ទំនងសិទ្ធិទទួលការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា*

នៅខែ វិច្ឆិកា បេក្ខជន និងក្រុមគ្រួសាររបស់ពួកគេនឹងទទួលព័ត៌មានថ្មីៗដែលទាក់ទងនឹងស្ថានភាពនៃសិទ្ធិទទួលបានឆ្នោតសម្រាប់ សាលា/កម្មវិធី នីមួយៗ ដែលពួកគេបានដាក់ពាក្យស្នើសុំ។ **នេះនឹងរាប់បញ្ចូលទាំងសិស្សដែលលិខិតដាក់ពាក្យស្នើសុំរបស់ពួកគេអាចនឹងបន្តទៅក្រុមពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា សម្រាប់ការពិនិត្យមើលឡើងវិញបន្ថែម។**




ស្ថានភាពនៃលិខិតដាក់ពាក្យស្នើសុំដែលអាចបង្ហាញសម្រាប់សិស្ស រួមមាន៖

- *អ្នកដាក់ពាក្យមិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យមួយ ឬលើសពីមួយ - ប្រសិនបើលោកអ្នកមិនប្រាកដថាមួយណា សូមសាកសួរអ្នកផ្តល់ឱវាទនៅសាលារបស់លោកអ្នក ឬគេហទំព័រ នៅទីនេះ។*
- *ការពិនិត្យមើលឡើងវិញនូវលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនទាន់សម្រេច* (**ប្រាប់ថាសិស្សមានសិទ្ធិទទួលបានការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា**)។
- *បានបញ្ជូន និងមានសិទ្ធិ។*

*កំណត់សំគាល់៖* ស្ថានភាពនៃ *ការពិនិត្យមើលឡើងវិញនូវលក្ខណៈវិនិច្ឆ័យបន្ថែមដែលមិនទាន់សម្រេច* ក៏ត្រូវបានប្រើប្រាស់សម្រាប់សិស្សានុសិស្សដែលមានអ្វីៗត្រូវតាមសិទ្ធិទទួលសម្រាប់សាលាដែលបង្រៀនពីជំនាញច្បាស់លាស់ និងការបង្រៀនដែលសិស្សរៀនតាមការធ្វើដោយផ្ទាល់ ហើយកំពុងបន្តទៅដំណាក់កាលនៃ ការសម្តែងសាកល្បង/ការបង្ហាញពីការរៀនតាមការធ្វើដោយផ្ទាល់ នៃការវាយតម្លៃ។ វា**មិនមែន**សម្រាប់តែសិស្សដែលមានការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នានោះទេ។

## *តើក្រុមពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នាធ្វើអ្វីខ្លះ?*

ការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា ធ្វើឡើងក្នុងខែ វិច្ឆិកា និងខែ ធ្នូ មុនពេលចាប់ឆ្នោត។ ក្រុមពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា ពិនិត្យមើលលិខិតដាក់ពាក្យ និងឯកសារគាំទ្រសម្រាប់សិស្សដែលមានសិទ្ធិ។

ក្រុមពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា មានសមាសភាពនៃបុគ្គលិកការិយាល័យកណ្តាល ដែលមកពីការិយាល័យផ្នែក សិស្សដែលសិក្សាផ្សេងពីគ្នា ការិយាល័យផ្នែក កម្មវិធី និងកម្មវិធីសិក្សា ភាសាចម្រុះ និងការិយាល័យផ្នែក ការពារ និងធ្វើអន្តរាគមន៍ ព្រមទាំងបុគ្គលិកមកពីសាលារៀនផ្អែកលើលក្ខណៈវិនិច្ឆ័យ។ សមាជិកក្រុមទាំងនេះមានជំនាញក្នុងការវិភាគឯកសារគាំទ្រ និងរបាយការណ៍សិក្សា ហើយនឹងពិនិត្យមើលលិខិតដាក់ពាក្យស្នើសុំ **មុនពេល**ចាប់ឆ្នោត។ ឯកសារដែលបានផ្តល់ឱ្យដោយអ្នកដាក់ពាក្យស្នើសុំ ជួយក្រុមពិនិត្យឡើងវិញសម្រេចថាតើសាលាអាចផ្តល់ការគាំទ្រដោយសមហេតុផលសម្រាប់សិស្សម្នាក់ៗដែលស្នើសុំចូលរៀនសាលាដែលផ្អែកលើលក្ខណៈវិនិច្ឆ័យដែរឬអត់។

## *លទ្ធផលនៃការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា*

នៅខែ មករា មុននឹងចេញលទ្ធផលឆ្នោត សិស្ស និងក្រុមគ្រួសារនឹងទទួលការទំនាក់ទំនងដែលទាក់ទងនឹងលទ្ធផលនៃការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នារបស់សិស្សពួកគាត់។

សិស្សណាដែលត្រូវបានចាត់ទុកថាមានសិទ្ធិចូលរៀននៅសាលា ឬកម្មវិធី ដែលផ្អែកលើលក្ខណៈវិនិច្ឆ័យតាមការចាប់ឆ្នោត ដែលជាលទ្ធផលនៃដំណើរការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នា នឹងត្រូវបានបញ្ចូលទៅក្នុងឆ្នោតសម្រាប់ សាលា/កម្មវិធី នោះ។ ពួកគេនឹងអាចមើលលទ្ធផលឆ្នោតនៅពេលលទ្ធផលទាំងអស់ត្រូវបានចេញផ្សាយនៅពេលក្រោយ ក្នុងខែមករា។

ដំណើរការពិនិត្យមើលឡើងវិញជាលក្ខណៈដោយឡែកពីគ្នាត្រូវបានចាត់ទុកថាជាបណ្ដឹងតវ៉ា។ បន្ទាប់ពីលទ្ធផលចុងក្រោយនៃការពិនិត្យឡើងវិញជាលក្ខណៈដោយឡែកពីគ្នាត្រូវបានប្រគល់ជូន នឹងមិនមានជម្រើសបណ្ដឹងតវ៉ាបន្ថែមទៀតសម្រាប់បេក្ខជន ឬក្រុមគ្រួសារ ឡើយ។